# សម្ភាសន៍ជាមួយឈ្មោះ ហាស់ យឿន ភេទប្រុស អាយុ៨៨ឆ្នាំ

## មុខងារសម័យខ្មែរក្រហមៈ ទាហានខ្មែរក្រហម

## ស្រុកកំណើតនៅភូមិចែឈូក ឃុំអន្លង់ជុំ ស្រុកសសរស្តម្ភ ខេត្តសៀមរាប

## សព្វថ្ងៃរស់នៅភូមិយាងវៀន ឃុំផ្គាំ ស្រុកស្វាយចេក ខេត្តបន្ទាយមានជ័យ

## ថ្ងៃទី៨ ខែធ្នូ ឆ្នាំ២០១០

## សម្ភាសន៍ដោយៈ ស៊ិន សុធីតា

## ០០ៈ៤៨ៈ២០

## ១៦ទំព័រ

ធីតា : កងចល័តនៅណា?

យឿន : កាលនោះខ្ញុំនៅស្រុកវ៉ារីន ។

ធីតា : វ៉ារីនហ្នឹងនៅណាទៅ?

យឿន : នៅជិតអន្លង់វែងហ្នឹង ។

ធីតា : វាវេញឬក៏វ៉ារីន?

យឿន : វ៉ារីន ។ កាលហ្នឹងខ្ញុំចល័តខ្ញុំនៅហ្នឹងឯង ដល់នេះទៅនៅចល័តបានប្រហែលជា៣ខែស្រាប់តែពេលនោះគេឲ្យខ្ញុំទៅនៅភ្លូវស្រែ ទៅនៅភ្លូវស្រែហើយតាចិនភូមិខ្ញុំកាលនោះគាត់ទៅអត់រួចផង ព្រោះគាត់ឈឺជង្គង់ហើយគាត់ទៅអត់រួចស្រាប់ពេលនោះខ្ញុំទៅលួចស្រូវគេ ដល់ពេលខែប្រួតខ្ញុំលួចស្រូវគេ លួចបានប្រហែលជាមួយតៅស្រាប់ពេលយប់ឡើងខ្ញុំយកក្របីទៅចង ហើយពួកខ្មែរក្រហមគេដឹងគេគុំចាប់ ដល់ពេលគុំចាប់ទៅខ្ញុំដឹងវាមានចំបើ៊ងអញ្ចឹងទៅខ្ញុំយកមកដេកវាល ហើយពួកវាដើរបុកតាមចំបើ៊ងរកខ្ញុំ បើសិនជាវាឃើញវាត្រូវស៊ីថ្លើមទាំងយប់ ដល់ពេលវាទៅបាត់ទៅខ្ញុំលូនចូលដុប ដល់ពេលលូនចូលដុបទៅព្រឹកឡើងមីងហឿនគាត់នៅចល័តគាត់សួថាអូនយប់មិញគេមានដេញចាប់ឯងទេ? ដល់ហើយខ្ញុំថាបាទ ។ ហើយគាត់សួថាឯងទៅធ្វើខ្មែរក្រហមទេ? ហើយខ្ញុំថាទៅឲ្យតែឲ្យខ្ញុំរស់ ដល់ពេលអញ្ចឹងទៅគេរើសយកខ្ញុំទៅ តែសម័យនោះគេអត់ធ្វើអីទេ ដើរតាមគេទៅ ។

ធីតា : អ្នកណាគេដែលម៉ោរើសហ្នឹង?

យឿន : ឈ្មោះមីងហឿនៗហ្នឹងគាត់ធ្វើប្រធានចល័តណ៎ា ធ្វើប្រធានចល័តនារី ។ ដល់ពេលនោះខ្ញុំក៏ទៅពេលទៅដល់គេកំពុងតែសូត្រអ្នកភូមិឬក៏សក្តភូមិអីចឹងទៅ ហើយខ្ញុំនឹកឃើញថានាយទុន

ប្រហែលជាអ្នកមានហើយ ហើយនឹកឃើញកសិករគឺជាអ្នកក្រព្រោះខ្ញុំជាអ្នកកសិករ ហើយផ្ទះខ្ញុំរនាបក៏បាក់អស់ ហូបបាយក៏មិនគ្រប់គ្រាន់ដល់ពេលនេះគេដាក់ឈ្មោះខ្ញុំឲ្យធ្វើខ្មែរក្រហម គេបើកកាំភ្លើងបើកអីឲ្យចឹងណា៎ ហើយឲ្យខ្ញុំយាមដើរមើលគេ ការពារដូចថាអ្នកណាលួចអីអញ្ចឹងទៅឲ្យចាប់ចង ដល់ពេលនោះឲ្យខ្ញុំទៅយាមចំការទៅយាមពេលយប់ ទៅយាមនោះទៅគ្នា១៥នាក់ កាលហ្នឹងខ្ញុំនៅជាមួយគណៈស្រុក អឿន។

ធីតា : គណៈស្រុក អឿន?

យឿន : បាទ។

ធីតា: គាត់នៅខាងណា?

យឿន : គាត់អ្នកខាងខេត្តក្រចេះ អាហ្នឹងស្រុកកំណើតរបស់គាត់។

ធីតា : អ៎។

យឿន : កាលហ្នឹងគាត់នៅខ្មែរក្រហម។

ធីតា : ចា៎។

យឿន : ដល់ពេលយប់ឡើងស្រាប់តែមានមនុស្សម្នាក់ទៅលួចពោត ក្មេងអាយុ២៥ហើយវាទៅលួចពោត ហើយពេលនោះខ្ញុំនៅកៀនផ្លូវស្រាប់តែវាទៅវាកាច់ហើយ ដល់ហើយខ្ញុំថាកាច់ប៉ុណ្ណឹងបានហើយចេញទៅវិញទៅ បើចូលទៅក្នុងទៀតប្រយ័ត្នមានមនុស្ស ដល់ហើយគេចេញម៉ោដល់ពេលចេញម៉ោ គេចាប់បានគេចងបណ្តើរម៉ោទាំងយប់ ហើយយកទៅវ៉ៃចោលទៅ។

ធីតា : ពួកគ្នាពូប៉ុន្មាននាក់?

យឿន : គ្នាពួកខ្ញុំដែលទៅយាមហ្នឹង?

ធីតា: ចា៎។

យឿន : ១៥នាក់។

ធីតា : ១៥នាក់?

យឿន : បាទ។

ធីតា : សុទ្ធតែប្រុសទាំងអស់?

យឿន: បាទ។

ធីតា : សុទ្ធតែប្រុសទាំងអស់?

យឿន : បាទ។ សុទ្ធតែពួកខ្មែរក្រហម។ បើខ្ញុំចុះឈ្មោះធ្វើខ្មែរក្រហមចាប់តាំងពីពេលដែលបានលួច

ស្រូវគេហ្នឹង ខ្ញុំរត់ពេលហ្នឹងបានរស់ម្ដង ហើយខ្ញុំទៅធ្វើខ្មែរក្រហមហ្នឹងដល់ពេលទៅធ្វើខ្មែរក្រហមគេឲ្យទៅយាមពោតហ្នឹង ដល់ពេលយាមពោតហ្នឹងម៉ោបានចាប់មនុស្សយកទៅវៃចោល តែខ្ញុំមិនបានវៃពួកគេទេតែពួកនោះទេជាអ្នកវៃ ហើយនឹកឃើញថាខ្ញុំគេចមិនផុតពីកន្លែងហ្នឹងទេនៅតែបានរស់ហ្នឹង ។

ធីតា ៖ ចា៎ ។

ឃឿន ៖ ដល់ពេលនោះទៅគេឲ្យខ្ញុំទៅនៅដីផ្សេង នៅដីវាលដែលគេហៅភូមិវេននៅខាងជើងវ៉ារីន ។

ធីតា ៖ ភូមិវេនហ្នឹងនៅតំបន់អីគេ?

ឃឿន ៖ នៅតំបន់ខាងខេត្តសៀមរាប ។

ធីតា ៖ ចា៎ ។

ឃឿន ៖ ខ្ញុំគេឲ្យដេញទាដេញអី ដល់ក្រោយម៉ោពួកខ្ញុំនេះដាំបាយឲ្យចល័ត ហើយកាលហ្នឹងបងប្រុសខ្ញុំគាត់កាន់ចល័ត៩០០នាក់ ។

ធីតា ៖ គាត់ឈ្មោះអីគេ?

ឃឿន ៖ ឈ្មោះ សាន់ គាត់កាន់ចល័ត៩០០នាក់ហើយអត់មានឲ្យបាយគ្នាស៊ីទេ គេធ្វើការវាល់ៗល្ងាចខ្ញុំដាំបាយនាំគ្នាដាំបាយស៊ីដាំអាផ្ទះថ្មអត់បានយកទៅឲ្យពួកចល័តម៉ោហូអស់ៗ ដល់ហើយគេខ្ញុំទៅដេកយាមរោងម៉ាស៊ីននោះ ដាក់ម៉ោដណ្ដើមគ្នាអស់ដល់ហើយគណៈស្រុកដឹងគេថាឃឹអានេះឲ្យម៉ោធ្វើការនេះវាទៅយកបាយឲ្យខ្លាំងឲ្យអីស៊ីអញ្ចឹងមិនកើតទេ ដល់ហើយគេបញ្ជូនខ្ញុំឲ្យទៅធ្វើយោធានៅគោកដូង ។

ធីតា ៖ គល់ដូង?

ឃឿន ៖ បាទ ។

ធីតា ៖ គោកដូងនៅខាងណាវិញ?

ឃឿន ៖ ភូមិគោកដូងនៅខាងត្បូងវ៉ារីន ។

ធីតា ៖ ខេត្តឧត្តមានជ័យមែន?

ឃឿន ៖ ខេត្តសៀមរាប ។

ធីតា ៖ ខេត្តសៀមរាប?

ឃឿន ៖ បាទ ។ ដល់ពេលនោះឡើងទៅស្រាប់តែខ្ញុំជញ្ជូនបានរយៈពេលបីថ្ងៃពួកយាយគាត់ចាស់ៗគាត់ទៅលួចស្រូវគេមួយក្ដាប់ដាក់ហោប៉ៅទៅ ដូចជាគ្រាប់ពោតណា៎គេ ហើយគេបណ្ដើរម៉ោគេជិះកង់ឲ្យគាត់ដើរ បើគាត់ដើរមិនទាន់ទេគេវៃគាត់ ហើយកាលហ្នឹងខ្ញុំចាំគាត់ចាស់ដូចអ៊ំខ្ញុំអញ្ចឹង

ណា៎ ហើយគាត់ហូបវាឆ្ងាក់ដល់ពេលហើយគាត់ថាអាអូនអើយឲ្យអ៊ំសុំទឹកហូបបន្តិចម៉ោ ដល់ពេលឲ្យទឹកហូបហើយគាត់ហ្នឹងក៏គេយកទៅដាក់ខ្នោះ ហើយមានរោងមួយធំគេដាក់ មនុស្សប្រហែលជា៣០០នាក់ គេដាក់ខ្នោះជើងទាំងពីរហើយចាក់ក្បាលគគ្នារួចទៅចាក់ចូល ៗ ទៅដល់ពេលក្រោយម៉ោបាន២ថ្ងៃក្រោយម៉ោខ្ញុំយាម ។

ធីតា : ដាក់ខ្នោះនៅណាដែរពូ?

យឿន : នៅគោកដូងហ្នឹងឯង ។

ធីតា : នៅគោកដូង?

យឿន : គេហៅភូមិគោកដូង ។

ធីតា : ចា៎!

យឿន : ស្រាប់តែដល់ពេលនេះឡើងទៅប្រពន្ធចៅហ្វាយស្រុកនោះឈ្មោះលោក សន ចៅហ្វាយស្រុកនៅគោកដូងនោះមេខ្មែរក្រហម ស្រាប់ពេលនោះទៅខ្ញុំគេទៅប្រជុំ ហើយតាសននោះទៅប្រជុំនៅណាទេកាលហ្នឹងដូចជាបាត់ដំបង គាត់បើកបានម៉ោពីរនាក់ប្រពន្ធគាត់ ប្រពន្ធគាត់ប្រហែលអៀនហើយព្រោះខ្ញុំថាអ៊ីអើយគិតមើលទៅ សូម្បីតែយើងហូបបាយរាល់ថ្ងៃហ្នឹងនៅតែឃ្លានចុះទម្រាំតែគ្នាអត់អញ្ចេះទៀត យកមកបន្តត់បាយបន្តត់ទឹក បើជាម៉ែឪយើងតើគាត់នឹងឃ្លានយ៉ាងណាទៅ កាលហ្នឹងខ្ញុំនៅលីវនោះ ដល់ហើយគាត់ថាមែនអាស៎អាតូចតោះដែទៅរកចាស់ ៗ ឲ្យបាន១០មកចែកដែលម៉ោក្រោយហើយខ្ញុំក៏លេង ដល់ពេលលេងអស់ទៅស្រាប់តែប្ដីគាត់ម៉ោថាអាតូចឯងម៉េចបានទៅលេងអាហ្នឹងធ្វើអី ដល់ហើយខ្ញុំថាខ្ញុំអាណិតពេក ហើយគាត់ថាបើឯងអាណិតឯងទៅចល័តវិញទៅ ដល់ហើយដេញខ្ញុំទៅចល័តវិញ បើមិនទៅចល័តទេនៅនេះគេវ៉ៃចោល ដល់ហើយសុខចិត្តទៅចល័ត ដល់ហើយត្រលប់ម៉ោចល័តវិញ ដល់ពេលម៉ោដល់ចល័តវិញយាយខ្ញុំគាត់នៅតែឯង គាត់ដើរអត់រួចទេធំតែក្បាលជង្គង់ទេ បាយក៏អត់មានហូបហើយខ្ញុំម៉ោដល់ស្វាត់ជ្រាប ទៅផ្ទះកាលហ្នឹងមានតែដើមឈើ មានតែដើមទន្រ្ទានខេត្រ ហើយគ្មានអ្នកណានៅទេ យាយខ្ញុំឃើញខ្ញុំគាត់យំគាត់ថាឯងម៉ោវិញ ហើយកូនហើយខ្ញុំថាបាទ ។

ធីតា : ឆ្នាំប៉ុន្មាន?

យឿន : កាលនោះឆ្នាំប៉ុន្មានទេខ្ញុំម៉ោផុះភ្លេចឆ្នាំ ។

ធីតា : កាលពូទៅអាយុប៉ុន្មាន?

យឿន : អាយុ៤៨ហើយ កាលនោះខ្ញុំទៅចល័តសម័យ៧៥ ខ្ញុំទៅប្រហែលជាក្រោយ៧៥មួយឆ្នាំ ។

ធីតា ៖ អញ្ចឹងមានតែ៧៦ ។

យឿន ៖ បាទ ៧៦ ។

ធីតា ៖ ៧៦ហ្នឹងពូទៅណាទៀត?

យឿន ៖ អាពេលហ្នឹងខ្ញុំត្រលប់ម៉ោចល័តវិញដល់ហើយគេបញ្ជូនទៅសាលារាជមណ្ឌលនៅខាងជើងស្រុកវ៉ារីន កាលហ្នឹងគេឲ្យទៅប្រូត ទៅប្រូតដេកប្រូតទៅដល់ហើយមានកុមារីតូចៗហ្នឹងវានាំគ្នារត់លេង ដល់ពេលរត់លេងទៅវានាំគ្នារត់លេងលើកណ្ដាប់ខ្ញុំរិះនឹងងាប់ទៀតថ្ងៃហ្នឹង វាចោទថាខ្ញុំហ្នឹងច្រានវាធ្លាក់ពីលើកណ្ដាប់ហើយសន្លប់ព្រោះវាលេងដេញគ្នា ដល់គេចោទថាខ្ញុំហ្នឹងជាអ្នកច្រានហើយក៏មានសាក្សីថាគាត់មិនបានច្រានទេវារអិលធ្លាក់ដោយខ្លួនឯង ហើយបានគេបញ្ជូនខ្ញុំឲ្យម៉ោធ្វើយោធាវិញ ឲ្យម៉ោធ្វើខ្មែរក្រហមវិញ ។

ធីតា ៖ អ៊ំ ។

យឿន ៖ ហើយគេថាមិត្តឯងទៅធ្វើខ្មែរក្រហមវិញទៅ ។

ធីតា ៖ ខាងណាដែលពូម៉ោធ្វើខ្មែរក្រហម?

យឿន ៖ ខ្ញុំម៉ោកន្លែងដដែលហ្នឹង ។

ធីតា ៖ អញ្ចឹងពូម៉ោពីដងមែន?

យឿន ៖ បាទខ្ញុំត្រលប់ម៉ោពីដង ខ្ញុំម៉ោដល់ក្រោយគេនេះបានពួកប៉ាវ៉ានេះ ពួកប៉ាវ៉ាខាងតាសំបុកៗនេះ កាលនោះសម្ដេចសីហនុនេះហើយ យប់នោះខ្ញុំគេឲ្យរត់តាមពីរនាក់អាមួយនៅគោកដូងយកសារម៉ោឲ្យគេ ខ្ញុំពីរបីដងនោះត្រលប់ទៅត្រលប់ម៉ោ ។

ធីតា ៖ សារហ្នឹងសរសេរថាម៉េចខ្លះ សារអីគេ?

យឿន ៖ សារបែបជាសំបុត្រ សំបុត្រថាដូចត្រូវឲ្យបញ្ជូនទ័ពទៅនេះទៅនោះ ដូចថាគេត្រូវយកមនុស្សទៅវ៉ៃចោលតែគេអត់ឲ្យយើងបើកទេណា៎ ។

ធីតា ៖ ចា៎ ។

យឿន ៖ គេអត់ឲ្យទេ ហាមដាច់ តិចថាឲ្យយើងជិះសេះទៅថាយកសារទៅឲ្យគេ ហើយកាលនោះអត់មានទូរស័ព្ទមានអីដូចយើងសព្វថ្ងៃនេះ មានតែជិះសេះទៅ ។

ធីតា ៖ ចា៎ ។

យឿន ៖ ទៅដល់ឲ្យគេរួចគេថាមិត្តឯងចាំហូបបាយនេះរួចចាំទៅ ដល់ពេលហូបរួចខ្ញុំម៉ោដល់កន្លែងយកហ្នឹងសុទ្ធតែស្ត្រីសមាគមន៍កាត់ដេរប៉ុននាងឯងគេរាងធំជាងបន្តិច គេថាថ្ងៃនេះរីងដៃរីងជើងណាស់សភាពការណ៍មិនស្រួលទេអញ្ចឹងយប់ហ្នឹងយើងទៅដេកព្រៃទៅ ខ្ញុំយប់មិញយល់សប្ដិ

អាក្រក់ណាស់ឃើញបាក់ធ្មេញ ហើយអ្នកខ្លះទៀតយល់សប្តិអាណាអាណី ដល់ហើយខ្ញុំថា តោះអញ្ចឹងយើងទៅដេកព្រៃ ស្រាប់តែយប់ឡើងពួកប៉ារ៉ាចូលម៉ោ ។

ធីតា ៖ ប៉ារ៉ាពីខាងណាវិញ?

ឃឿន ៖ ប៉ារ៉ាហ្នឹងខាងទាហានសីហនុ កាលហ្នឹងតាសីហនុទើបតែបង្កើតនោះ ហើយមានប្រធានគេហៅតាសំបុក ។

ធីតា ៖ តាសំបុក?

ឃឿន ៖ បាទ ។ នៅខាងតាសីហនុ ។

ធីតា ៖ មិនមែននៅខាងតាសឿន សាន ណាអី?

ឃឿន ៖ អត់ទេកាលនោះគាត់ទើបបង្កើតនៅខាងតាសីហនុ ។

ធីតា ៖ ហើយចុះពូដូចថាយកសារទៅឲ្យគេហើយគេថាម៉េចទៀត?

ឃឿន ៖ ពេលស៊ីបាយរួចហើយគេថាមិត្តឯងបើបានយកសាររួចហើយត្រលប់ទៅវិញចុះ ដល់ពេលខ្ញុំត្រលប់ម៉ោវិញម៉ោដល់កន្លែងហ្នឹងវិញបានស្រ៊ីៗសភាពការណ៍មិនស្រួលទេបាននាំខ្ញុំរត់ បានយប់ឡើងពួកប៉ារ៉ាចូលវ៉ៃហើយពួកខ្ញុំគេចយករួចខ្លួន ស្រាប់ក្រោយម៉ោទៀតព្រឹកឡើងកូនក្មេងធំៗគេខាងខ្មែរក្រហមគេម៉ោដល់ ម៉ោដល់យប់ហ្នឹងគេថាសភាពការណ៍មិនស្រួលទេផ្លូវបញ្ជូនមនុស្សដែលជាពួកនាយទុនបញ្ជូនទៅរៀន៩០០នាក់ដកពីតាមពីភូមិម៉ោ ដល់ពេលនេះគេយកទៅវ៉ៃហើយ ខ្ញុំអត់មានដឹងថាគេយកទៅវ៉ៃចោលណាំពុតែគេថាឲ្យម៉ោរៀនម៉ោអីហ្នឹងមានអីទៅដល់នោះគេ ស្រាតខោអាវអស់គេវ៉ៃ គេវ៉ៃនោះកូនង៉ាយំឡើងពេញហ្នឹង ហើយខ្ញុំលួចរត់ម៉ោវិញ ។

ធីតា ៖ ក្នុងឆ្នាំ៧៦ដែរមែនពូ?

ឃឿន ៖ ចុងឆ្នាំ៧៦ ។

ធីតា ៖ ចាំ ។

ឃឿន ៖ ដល់ពេលនោះខ្ញុំលួចរត់ម៉ោវិញ ហើយចុងឆ្នាំ៧៨នេះខ្ញុំគេឲ្យទៅ អាសំកាលហ្នឹងឲ្យខ្ញុំបរទេសទៅភូមិ ហើយខ្ញុំសុំច្បាប់គេទៅលេងផ្ទះ ដល់ពេលនោះបងខ្ញុំគាត់បរទេសបាក់ផ្លូវ ដល់ពេលបាក់ផ្លូវគេប្រុងយកបងខ្ញុំទៅវ៉ៃចោលថាបងខ្ញុំហ្នឹងខ្ចាំងអីណា ថាបងខ្ញុំហ្នឹងចង់ធ្វើឲ្យស្ទះដំណើរការមិនឲ្យជឿនលឿនអញ្ចឹងណាំ ថាយើងធ្វើអីដូចថាមិនជួយថែរយកដើងរាទឹក ហើយពីដើមប្រើតែផ្លូវឈើហើយយប់ហើយហ្នឹងហើយខ្ញុំបរទេសម៉ោដល់ស្រុក ហើយគេសួថាពីណាបរហ្នឹង ហើយខ្ញុំថាបងខ្ញុំគាត់ឈ្មោះសុង គាត់បងខ្ញុំបង្កើត ។

ធីតា ៖ គាត់អាយុប៉ុន្មាន?

យឿន ៖ បងគេបង្អស់ឆ្នាំរោងអាយុច្រើនណាស់ តែគាត់ស្លាប់បាត់ហើយ កាលហ្នឹងគាត់អាយុខ្ទង់ប្រហែល៣៨អីណ្ហឹង ។

ធីតា ៖ ចុះកាលហ្នឹងពូអាយុប៉ុន្មាន?

យឿន ៖ ខ្ញុំប្រហែលជាអាយុ១៥អីហ្នឹង មិនច្រើនទេ ។

ធីតា ៖ អ៊ំ ។

យឿន ៖ ដល់ពេលនោះខ្ញុំពួកអាពតគេថាម៉េចមិត្តឯងចង់ម៉េច ហើយបងខ្ញុំគាត់ថាខ្ញុំមានចង់ឲ្យវាបាក់ណាវាបាក់ខ្លួនវាតើ ដល់ហើយគេថាអាមិត្តឯងចង់តវ៉ាមែន តិចយកទៅវ៉ៃចោលឥលូវទើបបងខ្ញុំឈប់និយាយហើយខ្ញុំបរទេសម៉ោដល់ថាបងអើយ ដល់ហើយគេថាអ៊ើអាអូនអើយឯងម៉ោពីណាហើយខ្ញុំថាម៉ោពីកន្លែងមិត្តយើង ហើយគេថាបងអើយយកគោក្របីចងក្រោយម៉ោកុំឲ្យប្រធានសហករណ៍គេរករឿងណា៎ ។

ធីតា ៖ ប្រធានសហករណ៍ឈ្មោះអីគេពូ?

យឿន ៖ ភ្លេចបាត់ហើយព្រោះវាយូហើយ អ៊ំឈ្មោះតាដេត ។

ធីតា ៖ នៅវ៉ារីនហ្នឹងមែន?

យឿន ៖ បាទ! ដល់ពេលនេះទៅគេមាននារសាគេម្នាក់ ហើយគេថាមិត្តណាខ្លាំងតិចបាញ់បែករន្ធក្បាលឥលូវ ដល់ហើយខ្ញុំថាមិត្តបងខ្ញុំទើបតែម៉ោពីកន្លែងស្រុកហើយមិត្តបងមានការអីមែន? ដល់ហើយគេថាអ៊ំមិត្តយើងទេអី ហើយខ្ញុំថាបាទ ហើយគេថាអញ្ជើញចុះៗ ខ្ញុំម៉ោដល់នាំគ្នាដាំបាយដាំទឹកហើយគ្នាអ្នកអត់ៗហ្នឹងម៉ោពេញដល់ពេលល្ងាចម៉ោប្រធានសហករណ៍ហ្នឹងគេជួយអង្ករមួយតៅ ដល់ពេលគេឲ្យអង្ករមួយតៅម៉ោបានព្រលឹមឡើងខ្ញុំត្រលប់ម៉ោវិញ ដល់ត្រលប់ម៉ោដល់កន្លែងថ្មីវិញខ្ញុំជួបថ្មីអ្នកភ្នំពេញអ្នកជម្លៀសយើងនោះស្រី គ្នាដើរដូចជាដាច់បាយម៉ោពីណាទេ ហើយស្រីផងគ្នាដើរម្នាក់ឯង ខ្ញុំស្រណោះដែរកាលនោះបើសិនជាខ្ញុំធំវិញខ្ញុំយកធ្វើជាប្រពន្ធបាត់ហើយ បើជាស្រុកយើងសព្វថ្ងៃយកបាត់ហើយ ហើយកាលនោះខ្ញុំចែកទៅមួយស្និទដែលម៉ែខ្ញុំឲ្យម៉ោ ហើយគេសួថាមិត្តម៉ោពីណា ហើយខ្ញុំថាខ្ញុំម៉ោពីលេងម្ដាយ ហើយខ្ញុំសួថាមិត្តឯងម៉ោពីណាហើយគេថាខ្ញុំគ្មានគោលដៅទេ ហើយខ្ញុំថានេះមិត្តឯងយកចែកមួយស្និទទៅហូបទៅ ហើយគេថាមិនបាច់ទេមិត្តបងខ្ញុំដើរដល់ត្រឹមម៉ានយកត្រឹមហ្នឹងទៅ ហើយខ្ញុំនៅតែថានេះមិត្តឯងយកចែកមួយស្និទទៅ ហើយខ្ញុំម៉ោវិញទៅ ហើយកាលនោះសម័យ៧៩យួនឡើងទៅ គេឡើងទៅ ហើយកាលនោះគេហៅយើងថាយាកថុង ខ្ញុំរត់ម៉ោបន្ទាយ

ដល់ពេលចូលម៉ោដល់បន្ទាយខ្ញុំលាក់កាំភ្លើង ដល់ពេលក្រោយម៉ោយួនចូលដល់ថាកន្លែងនេះមានប៉ុល ពត មានអីទេ? ដល់ហើយខ្ញុំទេអត់មានទេខ្ញុំមិនមែនខ្មែរក្រហមទេ ក្រោយម៉ោទៀតបានខ្ញុំរត់ចេញម៉ោដល់ហើយបានធ្វើប៉ាភ៉ា ធ្វើប៉ាភ៉ាខាងតាសឿនសាន ហើយបានខ្ញុំនៅៗទៅហើយបានខ្ញុំមកបានប្រពន្ធនៅភូមិនេះ ។

ធីតា : បឹងអំពិលមែនពូ?

យឿន : បាទ ហើយភ្នែកខ្ញុំនេះគេខ្វេះចេញតើ ខ្ញុំដាក់ភ្នែកផ្សេង ។

ធីតា : អ៎ ។ កាលទៅធ្វើទាហានប៉ាភ៉ាហ្នឹងមែនពូ?

យឿនៈ បាទ ។ ក្រោយពីធ្វើប៉ាភ៉ាហ្នឹងគេវៃគ្នាតាមគោកមនតាមអីហ្នឹង ហើយទាហានខាងក្នុង ។

ធីតា : ទាហានខាងក្នុងទាហានអីគេពូ?

យឿន : ទាហានហ៊ុន សែន យើងនេះមិនទាហានហ៊ុន សែន បង្កើតជាមួយទាហានយួន ហើយខ្លះគេហៅទាហានខ្មែរកាលសម័យនោះ ។

ធីតា : ចា៎ ។

យឿន : ដល់ពេលនេះខ្ញុំឈប់វៃជាមួយទាហានក្នុងហើយវៃជាមួយទាហានពួកមនម្តង ។

ធីតា : ទាហានពួកមនទៀត?

យឿន : បាទ ។

ធីតា : ជនជាតិអីគេហ្នឹង?

យឿន : ជនជាតិខ្មែរយើងទាំងអស់ហ្នឹងឯង ។ នៅជាមួយយួនដែរនៅជាមួយខ្មែរដែរ ដល់ពេលក្រោយម៉ោខ្ញុំវៃជាមួយហ្នឹងរួច ខ្ញុំម៉ោវៃនៅភូមិបន្ទាយឆ្មាស្រុកថ្មពួក ខ្ញុំវៃបាញ់រថយន្តឆេះមួយគ្រឿង ហើយចាប់បានរថយន្តមួយគ្រឿងហើយចាប់បានកម្លាំង៣០០នាក់ ក្រោយម៉ោបានធ្វើរដ្ឋប្រហារឆ្នាំប៉ុន្មានទេធ្វើរដ្ឋប្រហាដូចជាឆ្នាំ៩៣មិនដឹងទេ ។ ខ្ញុំទៅវៃពួកខ្មែរក្រហមនៅអន្លង់វែងមួយសារទៀតកន្លែងតាម៉ុកនោះ ។

ធីតា : អ៎ពូទៅវៃដល់ហ្នឹងហ្មង?

យឿន : បាទ ។ ទៅវៃកន្លែងហ្នឹងហើយបានក្រោយម៉ោទៅវៃនៅកន្លែងប៉ៃលិនទៀត ។

ធីតា : ទៅរយៈពេលប៉ុន្មានដែរពូ?

យឿន : បាទ?

ធីតា : តាម៉ុកហ្នឹងរយៈពេលប៉ុន្មាន?

យឿន : វៃរយៈពេលជិតមួយខែ ។

ធីតា ៖ ជិតមួយខែ?

យឿន ៖ បាទ ៗ

ធីតា ៖ ហើយកាលហ្នឹងមានមនុស្សស្លាប់ច្រើនទេ?

យឿន ៖ មនុស្សស្លាប់ច្រើនដែរ ៗ ក្រោយម៉ោគេឲ្យទៅវ៉ៃនៅប៉ៃលិនហើយរៀបចំថាទៅវ៉ៃហើយហ្នឹង ដល់ពេលល្ងាចហ្នឹងចិខ្ញុំគាត់ឈឺធ្ងន់ដាច់បាយដាច់ទឹកទៅតែ៣វ៉ៃគេម៉ោតាមទៅខ្ញុំឈប់សង្គ្រាម តាំងពីពេលនោះរហូតម៉ោ ហើយធ្វើស្រែចំការទៅរកស៊ីចិញ្ចឹមកូនទៅ កូនវាច្រើនដែរកូន៥នាក់នោះ?

ធីតា ៖ ហើយពូម៉េចបានរបួស? ហើយរបួសយ៉ាងម៉េច?

យឿន ៖ យើងវ៉ៃទៅគេបាញ់ម៉ោ កាលនោះខ្ញុំកាន់មេកងរង ហើយខ្ញុំរបួសទាហានខ្ញុំស្លាប់អស់ពីរនាក់ ហើយមានរបួស៣នាក់ ខ្ញុំក៏របួសដែរ ៗ ដល់ពេលក្រោយម៉ោខ្ញុំទៅធ្វើការនៅថៃបែកសង្គ្រាម ៗ

ធីតា ៖ ធ្វើការនៅថៃឆ្នាំណា?

យឿន ៖ ទៅប្រហែលជា៣,៤ខែមុននេះឯង ៗ

ធីតា ៖ អ៊ំ ៗ

យឿន ៖ កាលហ្នឹងទៅផ្លូតទឹកទៅដល់ក្បាលគ្នាក៏បែកទៅ ៗ

ធីតា ៖ ពូខ្ញុំចង់សួបន្តិចអាកន្លែងមេកងហ្នឹង កាលពូធ្វើមេកងហ្នឹងម៉េច?

យឿន ៖ ធ្វើមេកងគេដឹកនាំគេ ៗ

ធីតា ៖ ដឹកនាំគេប៉ុន្មាននាក់?

យឿន ៖ ១០០នាក់ ៗ

ធីតា ៖ ១០០នាក់?

យឿន ៖ បាទ ៗ

ធីតា ៖ ហើយគេវ៉ៃពីខាងណាម៉ោខាងណាទៅ?

យឿន ៖ វ៉ៃអន្លុងវែងមែន?

ធីតា ៖ ចា៎ ៗ

យឿន ៖ ផ្លូវវ៉ៃទៅពីខាងជើង ៗ

ធីតា ៖ ពីបន្ទាយឆ្មាទៅមែន?

យឿន ៖ អត់ទេ ។ បន្ទាយឆ្មារ៉ៃពីដំបូង កាលមុនរដ្ឋប្រហា រឿងនេះពីបីសារនោះបើនិយាយឲ្យអស់ទៅ កាលខ្ញុំរ៉ៃបែករួច រ៉ៃមុនដំបូងខ្ញុំរ៉ៃបន្ទាយឆ្មា ដល់រ៉ៃបន្ទាយឆ្មារួចបានទៅរ៉ៃអន្លង់វែង ដល់ពេលរ៉ៃអន្លង់វែងរួចហើយមិនញ៉ើក ប៉ុន្តែធ្វើរដ្ឋប្រហាខាងក្នុងមួយសារដោយសារមានរឿងជាមួយហ៊ុន សែនហ្នឹងមួយសារនោះមានផ្ទុះខាងក្នុងហើយមិនរត់ម៉ោមួយសារ ដល់ពេលមួយសារក្រោយម៉ោមិនពួកខ្ញុំរត់ទៅរ៉ៃមួយសារហើយបានខ្ញុំឈប់ ។

ធីតា ៖ រដ្ឋប្រហាឆ្នាំ៧០ ?

យឿន ៖ បាទ ។

ធីតា ៖ ចុះអន្លាល់៧១ ,៧២ពូធ្វើអីគេ?

យឿន ៖ តាំងពី៧០ ,៧១ ,៧២ម៉ោខ្ញុំឈប់រហូតហ្នឹង ខ្ញុំធ្វើស្រែធ្វើចំការ ។

ធីតា ៖ ដល់ពេល៧៥ចាប់ផ្តើមចូល..?

យឿន ៖ បាទ ។

ធីតា ៖ អត់មានបានរៀនបានសូត្រអីទេ?

យឿន ៖ អត់មានបានរៀនទេ ខ្ញុំទៅរៀនទៅចល័តនោះ កាលនោះគេឲ្យទៅរៀនទៅចល័តនោះ ហើយរៀនផងគេឲ្យយើងកាប់ស្លឹកទន្រ្ទានខេត្រធ្វើជីផង គេឲ្យយើងទៅប្រមូលទន្រ្ទានខេត្រហើយប្រមូលអាចម៍គោម៉ោធ្វើជី

ដល់ក្រោយម៉ោគេឈប់ឲ្យរៀនហ្នឹងគេឲ្យយើងទៅចល័តរហូតហ្នឹង ។

ធីតា ៖ ចុះដូចរ៉ៃខាងទាហានប៉ុរ៉ាអីខាងណាអ្នកចាញ់?

យឿន ៖ កាលដែលរ៉ៃនោះខាងខ្ញុំឈ្នះខាងគេចាញ់ កាលនោះពួកខ្ញុំចាប់បានឡានប៉ុន្មានគ្រឿងនោះ ។

ធីតា ៖ ចាប់បានឡានអីគេខ្លះពូ?

យឿន ៖ ចាប់បានឡានដឹកទឹកហ្នឹងពីរ ។

ធីតា ៖ ឡានដឹកទឹក?

យឿន ៖ បាទ ។ បានរថក្រោះពីរគ្រឿង ហើយបាញ់ឆេះមួយគ្រឿង បាញ់នៅបន្ទាយឆ្មា ។

ធីតា ៖ នៅខាងបន្ទាយឆ្មាមែនពូ?

យឿន ៖ បាទ ។ បន្ទាយឆ្មាខេត្តឧត្តមានជ័យនេះ ។

ធីតា ៖ ចុះកន្លែងតំបន់បន្ទាយហ្នឹងពូមានដឹងទេថាហេតុអីបានជាគេទៅរ៉ៃនៅកន្លែងហ្នឹងវិញ?

យឿន ៖ កាលនោះបន្ទាយឆ្មានោះគឺជាយដែន ដល់ពេលជាប់ជាមួយជាយដែននោះកម្លាំងខ្លាំងវាទៅបន្ទាយឆ្មានេះឯង ។ បន្ទាយឆ្មាវាជិតជាយដែនដល់ពេលជាប់ជាយដែនទៅជាយដែនហ្នឹងគឺ

កម្លាំងខ្លាំងហើយកម្លាំងខាងក្នុងគឺដាក់តែមិនឲ្យប៉ារ៉ាអឺចុះឡើងបាន ដាក់ដូចជារបងលួស ដាក់មីន ដាក់ដុច ហើយបើសិនជាចុះម៉ោត្រូវដុចត្រូវអឺងាប់ កុំឲ្យវាងនាំទ័ពនាំកម្លាំងចូលខាងក្នុងបានធ្វើដូចជាខ្សែក្រវ៉ាត់ជាមួយជាយដែនថៃហ្នឹងឯង ។

ធីតា ៖ ហើយបន្ទាយឆ្មាហ្នឹងមនុស្សទៅច្រើននាក់ណាស់មែនទេពូ?

យឿន ៖ ច្រើន ៗ កាលនោះមានស្រុកភូមិ ហើយកម្លាំងខាងក្នុងមានប្រហែលជា៣០០នាក់ ហើយខ្ញុំចូលគេអូសតាំងពីល្ងាច ចូលទៅឈរទម្រាំភ្លឺបានគេឲ្យវ៉ៃដែលគេហៅថាវ៉ៃផ្កាវីកហ្នឹង ។

ធីតា ៖ អ្នកណាគេដែលហៅថាវ៉ៃផ្កាវីកហ្នឹង? គេប្រើពាក្យផ្កាវីក?

យឿន ៖ បាទ ៗ ចូលវ៉ៃផ្កាវីកហ្នឹងសុទ្ធតែមេៗគេរើស ហើយគេរើសតែអ្នកមានជំនាញៗ ហើយផ្កាវីកហ្នឹងវ៉ៃពីក្នុងម៉ោខាងក្រៅ ។

ធីតា ៖ យើងវ៉ៃទាហានខាង...?

យឿន ៖ ទាហានខាងក្នុង ៗ វ៉ៃផ្កាវីកហ្នឹងដូចថាបន្ទាយខ្លាំងនៅអញ្ចេះយើងនៅខាងនោះ ពេលដល់ម៉ោងដូចថាមេបញ្ជាថាម៉ោង៤ត្រូវផ្ទុះអញ្ចឹងម៉ោង៤ចាប់ផ្ដើមវ៉ៃខាងក្នុងតែម្ដង រួចបានគ្នាយើងកម្លាំងខាងក្រៅនេះបាញ់ចូល ដល់ពេលមើលទៅបាញ់ខ្លាំងហើយដូចថាបាញ់ច្រឡំគ្នាអញ្ចឹងត្រូវបាញ់ទៅខាងលើវិញ ។

ធីតា ៖ ហើយពូអ្នកខាងបាញ់ហ្នឹងដែរ?

យឿន ៖ ខ្ញុំអ្នកខាងវ៉ៃផ្កាវីកហ្នឹងឯង ។

ធីតា ៖ ផ្កាវីក?

យឿន ៖ បាទ ៗ

ធីតា ៖ ដឹកនាំមុខគេបុកម៉េចពូ?

យឿន ៖ បាទ ៗ ខ្ញុំជាកូនគេហើយកាលគេដកហ្នឹងគេដកយកតែមេៗទៅ តែមានមេបញ្ជាការបងគោឈា ជាមេបញ្ជាការធំនៅលើគេ ។

ធីតា ៖ ឈ្មោះគោឈា?

យឿន ៖ បាទ ៗ

ធីតា ៖ គោឈា តំបន់៣ ៗ តំបន់៣នៅណាវិញពូ?

យឿន ៖ នៅបឹងជុំនេះឯង ៗ

ធីតា ៖ បឹងជុំ?

យឿន ៖ បាទ ៗ

ធីតា ៖ តែ គោឈា ហ្នឹងគាត់ជាអ្នកដឹកនាំហ្មង?

យឿន ៖ បាទ ។ ដល់ពេលចូលវៃគាត់ជាអ្នកដើរបញ្ជាហ្មង កាលហ្នឹងគាត់ផ្កាយមួយ ។

ធីតា ៖ ចុះពូដូចថាពេលវៃអញ្ជឹងហើយអត់មានថាសម្រាកមានអីទេហ្នឹង?

យឿន ៖ វៃបែករួចបានសម្រាកហើយចូលឆែកឆេរនៅខាងក្នុងមានអ្នកណារបួសអញ្ជឹងយកមកព្យាបាល ហើយដឹកយកទៅអត់មានសម្រាកមានអីទេ ។

ធីតា ៖ ខាងណាអ្នកដឹក?

យឿន ៖ ខាងពួកប៉ុភាំនេះឯង ។

ធីតា ៖ អ៊ំ ។

យឿន ៖ បើអាមួយនោះវាមិនសមនឹងនេះផង គេចងវាដាក់សេរ៉ូមដាក់អីហើយវាស្រែកថាអញមិនចង់រស់ទេៗយកអញទៅបាញ់ទៅ ដល់ពេលវាងស្ងប់ពួកខ្ញុំចងជើងចងដៃជាប់ហើយពួកខ្ញុំទៅស៊ីបាយវាស្រាយខ្លួនវាបានស្ទុះទាញកាំភ្លើងរកបាញ់ពួកខ្ញុំ ដល់ហើយមេថាបើវាមិនចង់រស់ហើយយកវាទោបាញ់ចោលទៅ រួចហើយក៏គេយកទៅបាញ់ចោល តែឥលូវវានៅរស់តើនៅជួបប្រពន្ធជួបកូន បើខាងក្នុងខ្ញុំចាប់បានខ្ញុំមិនដែលធ្វើបាបទេ កាលខ្ញុំវៃក្នុងព្រៃហ្នឹង ។

ធីតា ៖ ព្រៃអីគេពូ?

យឿន ៖ ភូមិព្រៃ ។

ធីតា ៖ ភូមិព្រៃនៅណាវិញ?

យឿន ៖ នៅភូមិព្រៃកខាងនោះ ខាងស្វាយចេកនោះវិញ តែមិនដឹងខាងនាស្វាយចេកនោះទេ ហើយកាលនោះអាមួយនោះវៃគ្នាដាច់អស់១០កំណាត់ ខ្ញុំឲ្យទាហានសែងទៅព្យាបាលនៅមន្ទីរពេទ្យហើយពួកបារាំងពួកអីវាព្យាបាលឲ្យ ដល់ពេលវាជាទៅវាត្រលប់ទៅស្រុកវិញ កើតមួយជាតិនេះខ្ញុំសាងតែអំពើរល្អ ហើយអារឿងឆក់ប្លន់ទ្រព្យសម្បត្តិគេនោះមិនដែលទេ ព្រោះយាយខ្ញុំគាត់ហាមផ្តាច់អារឿងឆក់ប្លន់ទ្រព្យសម្បត្តិគេហើយខ្ញុំក៏ធ្វើតាមគាត់ទៅ ។

ធីតា ៖ ចុះភ្នែកពូម៉េចបាន...?

យឿន ៖ ត្រូវមីន ។

ធីតា ៖ ត្រូវមីនហ្មង?

យឿន ៖ បាទ ។

ធីតា ៖ នៅជាប់ដល់សព្វថ្ងៃនេះ?

យឿន ៖ បាទ ។ កាលហ្នឹងសុទ្ធតែអំបែងសុទ្ធ ។

ធីតា ៖  អ៎ៗ កាលហ្នឹងពូមានបានទៅទទួលសម្តេចទទួលអីទេកាលពេល៩៣?

យឿន ៖ កាលពេលសម្តេចតាម៉ោហ្នឹងមែនៗ

ធីតា ៖  កាល៨០ជាងពូនៅណា?

យឿន ៖ កាលនោះខ្ញុំនៅជំរុំបឹងអំពិលកាលនោះសម្តេចតាដែលម៉ោលេងតើ គាត់ចុះម៉ោខ្ញុំទៅទទួលតើៗ តែតាំងពីនោះម៉ោមិនដែលបានឃើញទេបានត្រឹមឃើញក្នុងទូរទស្សន៍   ហើយណាមួយយើងក្រដង ទូរទស្សន៍ក៏មិនមានមើលៗ

ធីតា ៖  ជំរុំបឹងអំពិលហ្នឹងភាគច្រើនសុទ្ធតែខ្មែរទេពូ?

យឿន ៖ បាទ! ខ្មែរយើងជំនាន់អ្នកតស៊ូសុទ្ធហ្នឹង ដូចជាទាហានដូចជាអីហ្នឹងៗ ហើយដូចអ្នកនៅលីវទៅបានប្រពន្ធបានអីហើយក៏ចេះតែរស់នៅហ្នឹងទៅ កាលហ្នឹងសម័យតស៊ូ មានបារាំងមានអីបើកអង្ករ បើកត្រីខ ហើយដូចថាថ្ងៃព្រហស្បត្តិថ្ងៃសុក្រអញ្ចឹងគេបើកឲ្យម្តង ហើយគេនៅនោះទៅគេលេងគេបង្កើតល្បែងរបាំ ហើយដល់ពេលបានមួយអាទិត្យទៀតគេបើកអង្កឲ្យ ឲ្យតែស្រីទេបើប្រុសអត់ឲ្យ បើអ្នកណាទាហាននៅតាមទាហាន ហើយមានប្រពន្ធនឹងកូនគេបើកឲ្យប្រពន្ធនឹងកូនទៀត តែបើឈឺអីអាចយកទៅកន្លែងពេទ្យព្យាបាលនៅពេទ្យហ្នឹងបាន ហើយពេទ្យសម័យនោះជួយព្យាបាលដោយស្មោះត្រង់ ហើយពេទ្យឥលូវនេះមិនបានទេមើលឃើញតែលុយទេៗ

ធីតា ៖  ចុះកាល៩៣ពូនៅហ្នឹងទៀតឬក៏ត្រលប់ម៉ោស្រុកវិញហើយ?

យឿន ៖ សម័យ៩៣?

ធីតា ៖  សម័យគេបោះឆ្នោតនោះ?

យឿន ៖ កាល៩៣គេបញ្ជូនត្រលប់ម៉ោស្រុកហើយៗ គេបញ្ជូនម៉ោភូមិនោះហើយ គេដឹកចេញម៉ោរួចបានខ្ញុំទៅបោះឆ្នោតនៅថ្មពួកៗ

ធីតា ៖  ខាងណាអ្នកដឹកម៉ោ?

យឿន ៖ គេថាខាងពួកបារាំងជូនម៉ោស្រុកវិញកំណើតវិញ ហើយគេមានឲ្យម្នាក់៥០ដុល្លាៗ

ធីតា ៖  ឲ្យតែអ្នកធ្វើទាហានដឹងតែគេឲ្យហ្នង?

យឿន ៖ អ្នកស្រុកក៏គេឲ្យដែរឲ្យតែនៅក្នុងជំរុំហ្នឹងៗ

ធីតា ៖  អ៎ដែលគេថានៅក្នុងសាយធូសាយប៊ីហ្នឹងមែន?

យឿន ៖ ដល់ពេលចេញពីបឹងជំរុំទៅខាងក្នុងវៃបែកទៅបានទៅជំរុំសាយធូទៀត  ទៅនៅជំរុំសាយធូហ្នឹងដល់ពេលវៃបែកទៅបានគេរត់ទៅនៅខាងសាយប៊ីៗ

ធីតា ៖  ចុះសាយធូអ្នកណាគេអ្នកគ្រប់គ្រង?

យឿន ៖ បើសាយប៊ីគាស៊ុន សាន ។

ធីតា ៖ ហើយពូមានដែលបានជួបគាត់ទេ?

យឿន ៖ ជួប ។

ធីតា ៖ ជួបគាស៊ុន សានហ្នឹងហ្មង?

យឿន ៖ បាទ ។

ធីតា ៖ គាត់ម៉ោលេងពូមែន?

យឿន ៖ គាត់ម៉ោលេងទាហានដូចថាទាហាន៥០០,៦០០នាក់អញ្ចឹងគាត់ម៉ោលេងទៅហើយយើងទៅទទួលទៅ ហើយគាត់ម៉ោដូចជាស្តេចដែរមានអង្គរក្សមានអី មានអ្នកថតកាមេរ៉ា មានអ្នកថតផ្សេងស្តាំអី ហើយពួកខ្ញុំរងចាំគាត់ម៉ោចាំចាប់ដៃ ហើយគាត់ម៉ោហើយគាត់ឡើងយន្តហោះទៅវិញទៅ បើនៅជំរុំនេះមានរដ្ឋបាលគេក្រោមគាស៊ុន សានសម្រាប់ត្រួតត្រាមើលការខុសត្រូវដូចថាមើលអង្គមើលអីដែលគេហៅថាអ្នកកាន់កាប់ រដ្ឋបាលហ្នឹងឈ្មោះវា ឡាយខេ នៅត្រពាំងថ្ម ។

ធីតា ៖ គាត់នៅត្រពាំងថ្ម?

យឿន ៖ នៅស្រុកត្រពាំងថ្ម ។

ធីតា ៖ ហើយអញ្ចឹងពូដូចថាពេលហ្នឹងគេសម្រុះសម្រួលគ្នាឬក៏ម៉េចទៀត?

យឿន ៖ កាលហ្នឹងខ្ញុំអត់ដឹងរឿងផង ស្រាប់តែពេលហ្នឹងពួកអន្តរជាតិចូលម៉ោដកអាវុធដកអី ដល់ពេលដកហើយបានគេថាឲ្យដឹកក្មេងចេញម៉ោត្រលប់ម៉ោស្រុកវិញម៉ោ ។

ធីតា ៖ ឆ្នាំណាដែលពូត្រលប់ម៉ោស្រុកកំណើតវិញ?

យឿន ៖ ឆ្នាំ៩០ ។

ធីតា ៖ ចុះ៩៣ពូនៅទេ ហើយម៉េចបាន៩០ពូនារទេសចេញម៉ោម៉េច?

យឿន ៖ កាលហ្នឹងយើងនៅជំរុំនៅឡើយហើយ៩៣ហ្នឹងមិនបោះឆ្នោត ខ្ញុំចេញម៉ោមុនមួយឆ្នាំកាលឆ្នាំ៩២ហើយឆ្នាំ៩៣មិនបោះឆ្នោត ។

ធីតា ៖ ហើយបានគេហៅទៅអ្នកណាដែលធ្លាប់នៅជំរុំហ្នឹងគេឲ្យលុយឲ្យអីអញ្ចឹងទៅ?

យឿន ៖ ពេលគេដឹកម៉ោគេហៅឈ្មោះយើងហើយចុះម៉ោពីលើឡានគេឲ្យលុយតែម្តង ឲ្យលុយយើងមានបុងមានអី ហើយដូចអត្តសញ្ញាណហើយនឹងសៀវភៅគ្រួសារយើងអញ្ចឹង ហើយយើងមានគ្នាប៉ុន្មាននាក់ដូចថាមានគ្នា៥នាក់ ដូចថាមានទាហាន៥នាក់ ឬក៏មានគ្រួសារពីនាក់អញ្ចឹងមានទាហានពីរនាក់បីនាក់ហើយចុះម៉ោឲ្យ ហើយហ្នឹងទាហានជាអ្នកគ្រប់គ្រង ហើយអង្ករអីគេ

ជួយមួយក្នុងរយៈមួយអាទិត្យ បើពេលនោះដាច់អញ្ជឹងទៅគេចាប់ផ្ដើមធ្វើស្រែហូបធម្មតា ទម្រាំតែយើងដូចថារើងដើរើងដើង ហើយខ្លះគ្នាធ្វើស្រែមិនទាន់បានពូកបារាំងគេជួយក្នុងរយៈ ៣ខែ៤ខែអញ្ជឹងទៅ ហើយខ្លះបែកកន្ទន់ដាក់ទឹកមួយហើយខ្លះទៀត ហើយខ្លះឲ្យញញួសម្រាប់ រៀបចំធ្វើផ្ទះធ្វើសំបែងអញ្ជឹងទៅណា ។

ធីតា : ចុះពូឥលូវពូមានដឹងថាអំពីរឿងការកាត់ទោសមេដឹកនាំខ្មែរក្រហមទាំង៥រូបអីទេពូ?

យឿន : អត់ដឹងភ្លេចអស់ហើយ បើនិយាយទៅចាំមិនបានហ្នង ។

ធីតា : គេកាត់ទោសខុចកាត់អីអត់មានដែលដឹងពីពត៌មានហ្នឹងទេ?

យឿន : ដឹងខ្លះដែរដែលគេផ្សាយតាមវិទ្យុ ម៉ោពីយើងមិនសូវយកចិត្តទុកដាក់ផង ។

ធីតា : ពូឥលូវមានការករណីកាត់ទោសលេខ០០២ទៀតអីចឹង ហើយវាមាន៤រូបណាំ មាននួន ជា មានខៀវ សំផន មានអៀង ធារិទ្ធ មានអៀង សារី ។

យឿន : បាទ ។

ធីតា : ហើយពូយល់ឃើញយ៉ាងម៉េចដែរចំពោះការកាត់ទោសមេដឹកនាំអញ្ជឹង ពូយល់ឃើញយ៉ាង ម៉េច?

យឿន : ខ្ញុំមិនដឹងយល់ឃើញថាយ៉ាងម៉េចទេ ព្រោះគិតស្មានមិនត្រូវព្រោះសុទ្ធតែជាអ្នកប្រល័យពូជ សាសន៍ មិនដឹងថាញ៉ែកថាម៉េចបើតាមនិយាយទៅកំហុសគាត់ច្រើនណាស់ សម្ដេចគាត់ជាអ្នក បង្កើតរឿងព្រោះគាត់ធ្លាប់ទៅនៅប៉េកាំងកាលហ្នឹង គាត់ថាគាត់ទៅនៅប៉េកាំងគាត់ទៅ ព្យាបាលនៅប៉េកាំងរហូត ដល់ពេលឲ្យទៅកាត់ទោសមិនដឹងថាម៉េចព្រោះសុទ្ធតែខុស បើ និយាយទៅតាមក្មេងវាពុទ្ធទំនាយវាអញ្ជឹងទៅហើយ ដូចគេថាមានផ្លូវអត់មនុស្សដើរ មាន ស្រូវមនុស្សស៊ី រឿងកាត់ទោសសម្រេចទៅលើអន្តរជាតិគេជាអ្នកសម្រេចទៅចុះ ឃើញថា ម៉េចឲ្យគេកាត់ទោសតាមដំណើរទៅ ។

ធីតា : ពូអាស្រ័យទៅលើតុលាកាហ្នង?

យឿន : បាទ ។ អាស្រ័យទៅលើតុលាកាកាត់ទោស ។

ធីតា : ចាំ ។

យឿន : ព្រោះតុលាកាគាត់ជាអ្នកជាអ្នកកាត់ទោសឲ្យយើងយុត្តិធម៌ បើតុលាកាកាត់ទោសប្រៀបដូច ជាជញ្ជីងអញ្ជឹង ខ្ញុំមើលទៅឃើញព្រោះខ្ញុំធ្លាប់នៅប្រទេសថៃគេចាប់បានគេហៅទៅកន្លែង តុលាការកាត់ទោសគេ តែយើងមិនមានទោសអីធ្ងន់ធ្ងរទេគ្រាន់តែយើងខុសច្បាប់ឆ្លងទៅ ប្រទេសគេតែប៉ុណ្ណោះ ហើយគេដាក់ជញ្ជីងយកទៅធ្វើ ។

ធីតា ៖ ពូទៅស្រុកអីគេ បាំងកកមែន?

យឿន ៖ បាទ ។

ធីតា ៖ ទៅធ្វើអីគេពូ?

យឿន ៖ កាលហ្នឹងទៅធ្វើការខាងដកដំឡូង កាលធ្វើការកសាងឃើញខ្ញុំឃើញថៅលីហ្វដិះសេះ ហើយមានការតឹងតែងណាស់ព្រោះមានគេយាមបីបួននាក់ខ្ញែងមិនងាយចូលបានទេ ។

ធីតា ៖ អញ្ចឹងពូមានអីចង់បន្ថែមទៀតទេដូចថាក្រោយសម័យខ្មែរក្រហមហើយមុនសម័យខ្មែរក្រហមវាខុសគ្នាម៉េច សម័យមុនហើយសម័យនេះខុសគ្នាយ៉ាងម៉េច?

យឿន ៖ ខុសគ្នាឆ្ងាយណាស់ ព្រោះសម័យនេះជឿនលឿនណាស់ ហើយសម័យខ្មែរក្រហមវេទនាណាស់ ក្រុមគ្រួសារខ្ញុំម្តងគេឲ្យបបរម្តងគេឲ្យបាយ ហើយប្អូនខ្ញុំទៅយកផ្លែខាំជងអីជង ហើយអត់មានអីស៊ីទេ មានគ្រាប់បាយប្រហែលមួយស្លាបព្រាចែកគ្នាហូប ហើយប្អូនស្រីខ្ញុំមួយនៅសព្វថ្ងៃនេះប្រហែលប៉ុណ្ណោះហើយ ដល់នេះម្តាយខ្ញុំមិនដឹងធ្វើម៉េចគាត់ទៅកាប់ចេកមួយស្និទម៉ោឲ្យកូនចែកបានម្នាក់ពាហូបទៅ ហើយខ្ញុំក៏មិនដឹងគិតថាម៉េចដល់សម័យនេះវាជឿនលឿនយើងហូបចុកអីបានតាមចិត្ត ទូរទស្សន៍ក៏មានមើល ទូរស័ព្ទក៏មានប្រើ តាំងពីចប់សង្គ្រាមម៉ោវាជឿនលឿនណាស់ តាំងពីហ៊ុន សែនគាត់ឡើងសោយរាជ្យម៉ោគោយន្តក៏មានប្រើ ម៉ាស៊ីនក៏មាន ដល់ពេលយូៗទៅលែងចង់ឈប់ប្រើគោហើយព្រោះវាជឿនលឿនពេក ខុសគ្នាត្រង់ថាក្នុងរយៈពេល៣ឆ្នាំហ្នឹង ។

ធីតា ៖ ចាំ ។ ពូឈ្មោះអីគេដែរពូ?

យឿន ៖ ឈ្មោះ ហាស់ យឿន ។

ធីតា ៖ ហាស់ យឿន?

យឿន ៖ បាទ ។

ធីតា ៖ អាយុប៉ុន្មានហើយពូ?

យឿន ៖ អាយុ៤៨ឆ្នាំ ។

ធីតា ៖ ស្រុកកំណើតនៅណាពូ?

យឿន ៖ ស្រុកកំណើតនៅឃុំអន្លង់ជុំ ។

ធីតា ៖ នៅភូមិអីគេ?

យឿន ៖ នៅភូមិចែឈូក ។

ធីតា ៖ ស្រុក?

យឿន ៖ ស្រុកសូទ្រនិគមន៍ ។

ធីតា ៖ ខេត្ត?

យឿន ៖ ខេត្តសៀមរាប ។

ធីតា ៖ ចុះបច្ចុប្បន្នគេហៅអី?

យឿន ៖ គេហៅភូមិយាងវេន ។

ធីតា ៖ ភូមិយាងវេន?

យឿន ៖ បាទ! ស្រុកស្វាយលេក ឃុំផ្គាំ ។

ធីតា ៖ ចុះពូមានដែលធ្លាប់ព្រួឈ្មោះ ពិន ទេ?

យឿន ៖ ពិន?

ធីតា ៖ ឈ្មោះ ឌុច តែគាត់ឈ្មោះពីរណា៎ ពូមានដែលព្រួទេ?

យឿន ៖ អត់ដែលព្រួទេ ។

ធីតា ៖ អញ្ចឹងអរគុណច្រើនហើយពូ ។

យឿន ៖ បាទ ។

«ចប់»